CONSERVATION INTERNATIONAL
Cambodia

# វគ្គបណ្តុះបណ្តាល
# ស្តីពី
# យេនឌ័រ និងការប្រើប្រាស់ធនធានធម្មជាតិ



# មាតិកា

ចំណងជើង

I. ផ្នត់គំនិត និងការប្រព្រឹត្តរបស់សង្គមមកលើកូនប្រុស និងស្រី
II. និយមន័យ
III. សមភាព និងសមធម៌យេនឌ័រ
IV. តួនាទីយេនឌ័រ
V. ទំនាក់ទំនងយេនឌ័រ
VI. យេនឌ័រ និងការប្រើប្រាស់ធនធានធម្មជាតិ

## I. ផ្នត់គំនិត និងការប្រព្រឹត្តិរបស់សង្គមមកលើកូនប្រុស និងស្រី

ជាទូទៅគ្រួសារ និងសហគមន៍ ភាគច្រើនមានការគិតទុក និងការប្រព្រឹត្តទៅលើកូនប្រុស និងកូនស្រីខុសៗគ្នា។ ការគិតទុកជាមុននេះត្រូវបានគិតទៅលើចំនុចមួយចំនួនដូចខាងក្រោមៈ

- ការទទួលបានការអប់រំ (កូនប្រុសរៀនបានច្រើនជាងកូនស្រី, កូនស្រីធំឡើងឆាប់ឲ្យរៀបការ)
- ការទទួលបានចំណីអាហារ (កូនប្រុសញាំុច្រើន ទទួលបានចំណីអាហារល្អៗបានច្រើនជាងកូនស្រី)
- សេរីភាពក្នុងការសេពគប់មិត្ត (កូនប្រុសសេពគប់មិត្តបានច្រើន, កូនស្រីឲ្យនៅផ្ទះ)
- កូនប្រុសក្លាហាន (ត្រូវបានបង្ហាត់ឲ្យមានភាពក្លាហាន) កូនស្រីសុភាព ត្រូវធ្វើការផ្ទះ មិនចាំបាច់រៀនច្រើនទេ និងជំរុញឆាប់រៀបការ។
- ការទទួលពត៍មានសង្គម (សុខភាព, ពត៍មានសង្គម)៖ កូនប្រុសចូលរួមក្នុងសង្គមច្រើនជាងកូនស្រី, ទទួលបានពត៍មានបានច្រើន និងហ៊ាននិយាយពីបញ្ហាសុខភាព។







## II. និយមន័យយេនឌ័រ និងភេទ

យេនឌ័រ: គឺជាការកំណត់របស់សង្គម សហគមន៍ និងគ្រួសារ ពាក់ពន្ធ័នឹងការបែងចែក ពលកម្ម ការអប់រំ សិទ្ធិអំណាច លំដាប់ថ្នាក់ ឋានៈ និងតួនាទីរបស់កូនប្រុស ស្រី បុរស និងស្ត្រី ហើយផ្លាស់ប្តូរបាន។

ភេទ: គឺជាលក្ខណៈជីវសាស្ត្រ ពីកំណើតដែលធម្មជាតិបានកំណត់ហើយ មិនអាចផ្លាស់ប្តូរបាន។

### ភាពខុសគ្នារវាងយេនឌ័រ និងភេទ

| តួនាទីភេទ<br>លក្ខណៈជីវសាស្ត្រ | តួនាទីយេនឌ័រ<br>កំនត់ដោយសង្គម |
|---|---|
| **មិនអាចផ្លាស់ប្តូរ និងកែប្រែបានទេ** | **អាចផ្លាស់ប្តូរ និងកែប្រែបាន** |
| ឧទាហរណ៍: មានតែស្ត្រីទេ ដែលអាចមានផ្ទៃពោះ និងអាចបំបៅកូនដោយទឹកដោះម្តាយ និងមានតែបុរសទេ ដែលអាចផ្តល់មេជីវិតបាន។ | ឧទាហរណ៍: ស្ត្រី និងបុរស អាចធ្វើការជាវិស្វករ និងអ្នកគ្រប់គ្រងបានដូចគ្នា។<br>ស្ត្រី និងបុរស អាចធ្វើការងារ ផ្ទះសម្បែង និងថែរក្សាកូនចៅបានដូចគ្នា។ |

## III. សមភាព និងសមធម៌យេនឌរ័

សមភាពយេនឌរ័: គឺជាសិទ្ធិស្មើៗគ្នា ក្នុងការទទួលខុសត្រូវ និងឱកាសរបស់ស្ត្រី និងបុរស កុមារី និងកុមារា។

សមធម៌យេនឌ័រ:គឺជាការចេះយោគយល់ អធ្យាស្រ័យគ្នា និងការចេះមានទំនួលខុសត្រូវនៅក្នុងសង្គម និងរង្វង់គ្រួសារ។

## IV. តួនាទី និងទំនាក់ទំនងយេនឌ័រ

### ១. ទំនាក់ទំនងយេនឌ័រ

គឺជាទំនាក់ទំនង ផ្នែកសេដ្ឋកិច្ច និងសង្គមរវាងមនុស្សប្រុស និងស្ត្រី ជាពិសេសការបែងចែកអំណាចរវាង ពួកគេ ។ ទំនាក់ទំនងទាំងនោះ គឺការកសាង និងជុំរុញដោយសង្គម ។ ទំនាក់ទំនងយេនឌ័រនេះជះផលប៉ះពាល់ ដល់តួនាទីរបស់ស្ត្រី និង បុរស នៅក្នុងសង្គមឆ្ពោះទៅដល់ការបាត់បងផលប្រយោជន៍ របស់ស្ត្រី ។ ទំនាក់ទំនងយេនឌ័រពាក់ព័ន្ធទៅជួរស្ថាប័ន និងបញ្ហាសង្គម ជៀសជាងទំនាក់ទំនងបុគ្គលរវាង បុរស និងស្ត្រី។

### ២.តួនាទី

តួនាទីយេនឌ័រ ត្រូវបានចែកចេញជា ០៣សំខាន់ៗ។

- តួនាទីមានប្រាក់កំរៃ៖ គឺជាការងារទាំងឡាយដែលទទួលប្រាក់កំរៃមានដូចជា:



  ការងារមន្ត្រីរាជការ, លក់ម្ហូបអាហារ, ការងារអង្គការនានា, នេសាទ......
- តួនាទីគ្មានប្រាក់កំរៃ៖ គឺជាការងារទាំងឡាយដែលមិនទទួលបានប្រាក់កំរៃ ដូចជា: ការងារថែទាំកូន, ថែទាំផ្ទះសំបែង, ដាំស្លរ, កាប់អុស.....
- តួនាទីសហគមន៍៖ គឺជាប្រភេទការងារស្ម័គ្រចិត្ត និងជាការងារដែលជួយអភិវឌ្ឍន៍សហគមន៍ដូចជា ធ្វើ និងជួសជុលសាលា, ធ្វើអនាម័យក្នុងភូមិ, ធ្វើបុណ្យក្នុងភូមិ និងការងារចូលរួមជាច្រើនក្នុងការអភិវឌ្ឍន៍ភូមិ ឃុំ សង្កាត់។

**សារៈសំខាន់នៃការងារទាំង០៣ប្រភេទ**៖ ការងារទាំងនេះមានតម្លៃ និងមានសារៈសំខាន់ដូចគ្នា មានទំនាក់ទំនង និងជួយបំពេញឲ្យគ្នាទៅវិញទៅមក ដោយមិនអាចកាត់ផ្តាច់មួយណាបានឡើយ។ ការងារផ្ទះបានជួយបំពេញឲ្យការងារក្រៅផ្ទះ រឺការងាររកប្រាក់ចំណូល ហើយក៏មិនអាចកាត់ផ្តាច់ការងារចូលរួមក្នុងការងារសហគមន៍ផងដែរ។ ឧទាហរណ៍៖ អ្នកចង់ទៅលក់ដូរនៅឯផ្សារ រត់ម៉ូតូឌុប រឺការងារសំណង់ បើគ្មានអ្នកធ្វើការងារផ្ទះ ដូចជាការដាំស្លរ ថែទាំផ្ទះសំបែង និងកូនចៅ អ្នកមិនអាចទៅធ្វើការងារទាំងនោះបានងាយស្រួលឡើយ។ ការជួយរំលែកការងារគ្នាទៅវិញទៅមក នឹងនាំមកនូវការឲ្យតម្លៃដល់គ្រួសារ និងធ្វើឲ្យគ្រួសារមានសុភមង្គល មានការរីកចំរើន ធ្វើឲ្យចំណេញពេលវេលា សម្រាប់ប្រកបរបរផ្សេងៗទៀត និងកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ។





៣. **សារៈសំខាន់នៃការចូលរួមរបស់ស្ត្រី**

- ស្ត្រីគឺជាធនធានមនុស្សដ៏សំខាន់ ស្ត្រីមានគំនិតប្រាជ្ញា ភាពវៃឆ្លាត អាចជាអ្នកធ្វើសេចក្តី  សម្រេចចិត្ត និងអ្នកដឹកនាំ នៅគ្រប់លំដាប់ថ្នាក់ ។
- ស្ត្រី អាចយល់សុខទុក និងតម្រូវការពិតរបស់ស្ត្រីដូចគ្នា ។
- ស្ត្រី អាចបង្ហាញ/ធ្វើជាគំរូ អ្នកដឹកនាំល្អ ដល់ក្មេងស្រី និងសង្គមទាំងមូល ។

**៤. សារៈសំខាន់នៃការបញ្ជ្រាបយេនឌ័រ**

- សង្គមមានការយល់ដឹង នឹងជ្រួតជ្រាបពីយេនឌ័រ
- វិភាគយ៉ាងលំអិត ពីភាពខុសប្លែកគ្នា ពីយេនឌ័រទៅក្នុងសង្គម
- បញ្ចូលបញ្ហាទាំងនោះ ទៅក្នុងគោលនយោបាយ ផែនការកម្មវិធី និង គម្រោងនានា

## V. យេនឌ័រ និងការប្រើប្រាស់ធនធានធម្មជាតិ

**ធនធានធម្មជាតិ**៖គឺជាធនធានដែលកើតឡើងដោយឯកឯង មានដូចជា ទឹក ដី ព្រៃ ពន្លឺព្រះអាទិត្យ ខ្យល់...។



ព្រែក/អូរ



ទន្លេ និងព្រៃលិចទឹក



ត្រី

**ការប្រើប្រាស់ធនធានធម្មជាតិ**៖ធនធានធម្មជាតិ បានផ្តល់នូវសារៈសំខាន់ណាស់ដល់ការរស់នៅរបស់មនុស្សលើភពផែនដី តាមរយៈផ្តល់នូវ អាហារ, ថ្នាំសង្កូវ, ទឹកស្អាត, ខ្យល់អាកាសបរិសុទ្ធ, មុខរបរចិញ្ចឹមជីវិត......។ ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជននៅប្រទេសក្រីក្រ/ប្រទេសកំពុងអភិវឌ្ឍន៍ គឺអាស្រ័យទៅនឹងលក្ខខណ្ឌធម្មជាតិ ដូចជាការដាំដុះ, ការនេសាទ ជាដើម។ ក្នុងនោះស្ត្រីជាអ្នកដើរតួរយ៉ាងសំខាន់ក្នុងការប្រើប្រាស់ធនធានធម្មជាតិទាំងនេះ។ ពួកគេបានប្រើប្រាស់ធនធានទាំងនោះ ជាចំបងក្នុងការប្រកបរបរជាលក្ខណៈខ្នាតតូច និងធំ សម្រាប់ចិញ្ចឹមជីវិតក្នុងគ្រួសារ និងសហគមន៍។ក្នុងនោះ តាមរយៈសិក្សា ការប្រើប្រាស់ធនធានធម្មជាតិ ស្ត្រីអាចរកប្រាក់ចំណូលបាន ៩០%នៃប្រាក់ចំណូលសរុប ចំណែកបុរសអាចរកត្រលប់បានប្រហែល ៣០% ទៅ៤០%។





**<u>បញ្ហាប្រឈម</u>**៖នៅរយៈពេល ៥០ឆ្នាំចុងក្រោយនេះ ប្រព័ន្ធអេកូឡូស៊ី បានផ្លាស់ប្តូរយ៉ាងខ្លាំងជាងរយៈការនៃការកកើតរបស់មនុស្សលោក។ បញ្ហាទាំងនេះ បានកើតឡើងដោយសារតែកំណើនហួសហេតុនៃតម្រូវការរបស់មនុស្ស ដោយប្រើប្រាស់ធនធានធម្មជាតិលើសលប់តាមរយៈ៖

- ការកាប់បំផ្លាញព្រៃឈើ/ព្រៃលិចទឹក
- ការនេសាទត្រីហួសហេតុ
- ការបំពុលទឹកតាមរយៈការរស់នៅ/ឧស្សាហកម្ម/វារីអគ្គិសនី
- ការបំពុលខ្យល់តាមរយៈ បំភាយឧស្ម័នពុលក្នុងបរិយាកាស









**ការចូលរួមរបស់ស្រ្តីក្នុងកិច្ចការពារធនធានធម្មជាតិ**៖តាមរយៈបញ្ហាកើតឡើងខាងលើ ស្រ្តី,កុមារតូច និងមនុស្សវ័យចាស់ ជាជនដែលងាយរងគ្រោះជាងគេ។ ម៉្យាងទៀត ដោយសារតែមិនមានការចូលរួមរបស់ស្រ្តីក្នុងកិច្ចការពារធនធានធម្មជាតិ បានធ្វើឲ្យមានការបាត់បង់នូវសម្លេងមួយភាគធំក្នុងការការពារបរិស្ថាន។ ការចូលរួមរបស់ស្រ្តីក្នុងកិច្ចការពារធនធានធម្មជាតិ និងថែរក្សាបរិស្ថានគឺពិតជាមានសារៈសំខាន់ណាស់ក្នុងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាព តាមរយៈការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗ។ ស្រ្តីអាចចូលរួមក្នុងកិច្ចការពារធនធានធម្មជាតិតាមរយៈការបញ្ចូលសមាសភាពរបស់ខ្លួនក្នុងការងារសហគមន៍ឲ្យបានច្រើនដើម្បីមានឱកាសដើម្បី

- បង្កើនសម្លេងកាន់តែច្រើនក្នុងកិច្ចការងារបរិស្ថាន តាមរយៈការប្រជុំលើកឡើងនូវបញ្ហាប្រឈមផ្សេងៗ
- ការធ្វើសេចក្តីសម្រេចចិត្ត ដោះស្រាយបញ្ហា លើកឡើងនូវផែនការផ្សេងៗ
- ផ្តល់ជាគំនិតយោបល់/ប្រឹក្សាយោបល់ដល់ក្រុមបុរសៗ

